01028979


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**លេខ/N°: D190/1/2**

***តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ០៧)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម** Rowan DOWNING
**ចៅក្រម នី ថុល**
**ចៅក្រម** Chang-Ho CHUNG
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 10 / 2014
ម៉ោង (Time/Heure): 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ: (សំណៅកោសលុប)**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ**

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សូវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Annie DELAHAIE
Laure DESFORGE
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Emmanuel JACOMY
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
François GAUTRY
Martine JACQUIN
Beini YE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបាន "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើនានារបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ" ដែលបានដាក់ជាភាសាអង់គ្លេស កាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៤ និងជាភាសាខ្មែរនៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ ("ម្ចាស់បណ្តឹងឧទ្ធរណ៍" និង "បណ្តឹងឧទ្ធរណ៍")[1]

## I. សេចក្តីផ្តើម

1. បណ្តឹងឧទ្ធរណ៍ទាក់ទងនឹងសេចក្តីសម្រេច ដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ដោយបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី ដែលបានដាក់ដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានដែលថា ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនមែនជា "ជនត្រូវចោទ" បើតាមអត្ថន័យនៃវិធានផ្ទៃក្នុង ហើយមិនមានតួនាទីក្នុងការដាក់សំណើឡើយ ("សេចក្តីសម្រេចដែលរងការជំទាស់")។

### ក. សាវតារ

2. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី នៅពេលនោះ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទៅសហចៅក្រមស៊ើបអង្កេត ដែលជាការបើកផ្លូវ និងចាប់ផ្តើមជាផ្លូវការ ការស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មដែលម្ចាស់បណ្តឹងឧទ្ធរណ៍ រួមជាមួយអ្នកដទៃទៀត ត្រូវបានចោទប្រកាន់ថាត្រូវទទួលខុសត្រូវ[2]។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[3] និងថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤[4]។

---

[1] ឯកសារD190/1/1។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា, ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារD1។ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ស្តីពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី, ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩,ឯកសារD1/1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់របស់សហព្រះរាជអាជ្ញា ទាក់ទងទីតាំងឧក្រិដ្ឋកម្មតំបន់ ១ និងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម, ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ D65។

[4] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាលើយេនឌ័រ , ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D191។

3. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ និងនៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ អង្គភាពគាំពារការការពារក្តី បានស្នើសុំឱ្យជនសង្ស័យក្នុងសំណុំរឿង ០០៤ អាចចូលពិនិត្យមើលសំណុំរឿង និងទទួលបានសិទ្ធិក្នុងនីតិវិធីផងទៃទៀត រួមទាំងសិទ្ធិចូលរួមក្នុងកិច្ចស៊ើបអង្កេត ដូចមានចែងក្នុងវិធានផ្ទៃក្នុង វិធាន ៥៥(៨) និង ៥៥(១០)[5]។ នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត (ចៅក្រម យូ ប៊ុនឡេង និង ចៅក្រម Blunk) បានបដិសេធសំណើសុំ ដោយសារតែ "ជនសង្ស័យ" រួមទាំងម្ចាស់បណ្តឹងឧទ្ធរណ៍ផង មិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការ តាមនីតិវិធីដែលមានចែងក្នុងវិធាន ៥៧ នៃវិធានផ្ទៃក្នុង ដូច្នេះពួកគេគឺមិនមែនជា "ភាគីនៃកិច្ចដំណើរការនីតិវិធី" នោះឡើយ ហើយផលប្រយោជន៍របស់ពួកគេក៏មិនត្រូវ "ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ" ដោយសារតែកិច្ចស៊ើបសួរ នោះដែរ[6]។

4. នៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៅពេលនោះ (ចៅក្រម KASPER-ANSERMET) បានជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ថា "លោកត្រូវបានជាប់ឈ្មោះថាជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរកំពុងបន្តដំណើរការ" ហើយថា "អនុលោមតាមវិធានផ្ទៃក្នុងនៃអ.វ.ត.ក[វិធាន ២១(១)(ឃ)], សិទ្ធិ និងការធានានានានៅក្នុងដំណើរការនីតិវិធី ក្នុងឋានៈជាជនសង្ស័យ រួមមានសិទ្ធិមានមេធាវីការពារខ្លួនតាមការជ្រើសរើសរបស់ខ្លួន [និង] សិទ្ធិមានលទ្ធភាពទទួលបានឯកសារសំណុំរឿង" ("ការជូនដំណឹងថ្ងៃទី ២៩ ខែ កុម្ភៈ")[7]។

---

[5] លិខិតរបស់ប្រធានអង្គភាពគាំពារការការពារក្តី ផ្ញើជូនសហចៅក្រមស៊ើបអង្កេតដែលមានចំណងជើងថា "លិខិតរបស់អង្គភាពគាំពារការការពារក្តី ស្តីពីសិទ្ធិការពារក្តី នៅក្នុងសំណុំរឿង ០០៣ និង ០០៤", ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារ D4.1.29។ លិខិតរំលឹកលើលិខិតរបស់អង្គភាពគាំពារការការពារក្តី ស្តីពីសិទ្ធិការពារក្តី នៅក្នុងសំណុំរឿង ០០៣ និង ០០៤, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ A1/1។

[6] លិខិតរបស់សហចៅក្រមស៊ើបអង្កេត ផ្ញើជូនប្រធានអង្គភាពគាំពារការការពារក្តី ដែលមានចំណងជើងថា "ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសិទ្ធិការពារក្តី នៅក្នុងសំណុំរឿង ០០៣ និង ០០៤", ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០,ឯកសារ D4.1.31។

[7] ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន២១(១)(ឃ)], ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ និងត្រូវបានជូនដំណឹងនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ D110។ សូមមើលផងដែរ លិខិតផ្ញើជូនអង្គភាពគាំពារការការពារក្តី ស្តីពីការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធានផ្ទៃក្នុង ២១(១)(ឃ)], ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២, ឯកសារ D111 កថាខណ្ឌ ៤។

5. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើដល់សហចៅក្រមស៊ើបអង្កេតឱ្យចេញដីកាបង្គាប់ដល់ការិយាល័យរដ្ឋបាល ឱ្យផ្តល់លទ្ធភាពដល់គាត់ក្នុងការចូលពិនិត្យមើលសំណុំរឿង ក្នុងសំណុំរឿង ០០៤ ("សំណើចូលពិនិត្យមើលសំណុំរឿង")[8]។ សំណើត្រូវបានអះអាងសាជាថ្មីនៅក្នុងលិខិតមួយដែលបានផ្ញើរជូនសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២[9] ហើយបន្ទាប់មកផ្ញើរជូនម្តងទៀតនៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣[10]។ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ម្ចាស់បណ្តឹងឧទ្ធរណ៍បានស្នើសុំបន្ថែមដល់សហចៅក្រមស៊ើបអង្កេត ឱ្យអនុញ្ញាតឱ្យគាត់អាចចូលរួមក្នុងកិច្ចស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ដោយសុំមានវត្តមាននៅក្នុងពេលស្តាប់ចម្លើយសាក្សី ហើយនឹងសុំអនុញ្ញាតដាក់សំណួរទៅកាន់សាក្សីទាំងនោះ ("សំណើសុំចូលរួមក្នុងកិច្ចស៊ើបអង្កេត")[11]។

6. នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធលើសំណើសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត ("សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើការចូលរួម")[12]។ ជាដំបូង សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាឡើងវិញលើផ្នែកមួយចំនួននៃសេចក្តីជូនដំណឹងថ្ងៃទី ២៩ ខែ កុម្ភៈ ដែលផ្តល់សិទ្ធិដល់

---

[8] សំណើជាបន្ទាន់សុំដីកាបង្គាប់ឱ្យការិយាល័យរដ្ឋបាលអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តី ពិនិត្យមើលសំណុំរឿង, ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២,ឯកសារ D121/2/1.1.1។

[9] លិខិតរបស់លោក ម៉ុម លុជ្ស លោក Richard ROGERS និងលោក Goran SLUITER ផ្ញើជូនសហចៅក្រមស៊ើបអង្កេត មានចំណងជើងថា "សិទ្ធិ [redacted] ក្នុងការទទួលបានព័ត៌មាន ស្តីពីប្រភេទ និងមូលហេតុនៃបទចោទមកលើរូបគាត់ និងសិទ្ធិទទួលបានសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់ត្រៀមរៀបចំការពារក្តីរបស់ខ្លួន" ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារD121/1។

[10] លិខិតរបស់លោក ម៉ុម លុជ្ស និងលោក Goran SLUITER ផ្ញើជូនសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា "ពាក់ព័ន្ធការដែលសហចៅក្រមស៊ើបសង្កេត មិនបានផ្តល់សិទ្ធិចូលពិនិត្យមើលសំណុំរឿង ទៅសហមេធាវីរបស់ [redacted]" ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារD122/7។

[11] លិខិតរបស់លោក ម៉ុម លុជ្ស លោក Richard ROGERS និងលោក Goran SLUITER ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ដែលមានចំណងជើងថា "ការចូលរួមរបស់មេធាវីការពារក្តី ក្នុងដំណើរការស៊ើបអង្កេតសំណុំរឿង ០០៤, ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D121/3។

[12] សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត, ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣, ឯកសារ D121/4។

01028983



ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការចូលពិនិត្យមើលសំណុំរឿង ហើយបានបដិសេធចោលសិទ្ធិទាំងនោះ[13]។ បន្ទាប់មកសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលមិនត្រូវបានចោទប្រកាន់ជាផ្លូវការនោះ គឺមិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីទេ ដូច្នេះគាត់មិនមានសិទ្ធិចូលរួមក្នុងការស៊ើបអង្កេត ឬចូលពិនិត្យមើលសំណុំរឿងឡើយ ដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក[14]។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ដោយសារមិនមានការចោទប្រកាន់ជាផ្លូវការប្រឆាំងម្ចាស់បណ្តឹងឧទ្ធរណ៍ ទើបមិនមានហេតុផលផ្សេងទៀតដែលចាំបាច់សម្រាប់ការចូលពិនិត្យមើលសំណុំរឿង ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់ឡើយ[15]។

7. នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការចូលរួមកិច្ចស៊ើបអង្កេត ទៅអង្គបុរេជំនុំជម្រះ ("បណ្តឹងឧទ្ធរណ៍លើការចូលរួម")[16]។ នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានប្រកាសថា ខ្លួនមិនអាចស្វែងរកសម្លេងគាំទ្រភាគច្រើនចំនួនបួននាក់ ដែលចាំបាច់សម្រាប់ការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ហើយដោយអនុលោមទៅតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការចូលរួមកិច្ចស៊ើបអង្កេត "ត្រូវតម្កល់ទុកជាបានការ" ("ការពិចារណាពីបណ្តឹងឧទ្ធរណ៍")[17]។ ចៅក្រមអង្គបុរេជំនុំជម្រះមិនយល់ស្របជាមួយគ្នា អំពីឋានៈផ្លូវច្បាប់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ព្រមទាំងកម្រិតនៃសិទ្ធិរបស់គាត់នៅក្នុងដំណាក់កាលនេះ ក្នុងកិច្ចដំណើរការនីតិវិធី។ ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី សម្រេចថា ម្ចាស់បណ្តឹងឧទ្ធរណ៍គឺជា "ជនសង្ស័យ" ដោយផ្អែកលើអង្គហេតុដែលថា គាត់មិនត្រូវបានចោទប្រកាន់ជាផ្លូវការ ហើយបានសន្និដ្ឋានថាម្ចាស់បណ្តឹងឧទ្ធរណ៍មិន

---

[13] សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើការចូលរួម, កថាខណ្ឌ ៤៩។

[14] សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើការចូលរួម, កថាខណ្ឌ ៣៦ ដល់៤៩។

[15] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥០ ដល់៦០។

[16] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច បដិសេធលើសំណើរបស់ក្រុមការពារក្តី សុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត, ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៣, ឯកសារD121/4/1/1។

[17] ការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធលើសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត, ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤, ឯកសារ D121/4/1/4 កថាខណ្ឌ ១៥ និង ១៦។

មានសិទ្ធិ ក្នុងការប្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរឡើយ យោងតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យប្ដឹងឧទ្ធរណ៍បានតែសម្រាប់ "ជនត្រូវចោទ" ឬ "ជនជាប់ចោទ" (មតិយោបល់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី)[18]។ ផ្ទុយទៅវិញ ចៅក្រម CHUNG និងចៅក្រម DOWNING យល់ឃើញថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបានដាក់ទោសហចៅក្រមស៊ើបអង្កេត គឺជា "ជនត្រូវចោទ" តាមអត្ថន័យនៃវិធានផ្ទៃក្នុង ដូច្នេះត្រូវមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង តាមរយៈមេធាវីរបស់គាត់ ហើយត្រូវស្ថិតក្រោមលក្ខខណ្ឌកម្រិតដែលកំណត់ដោយសហចៅក្រមស៊ើបអង្កេត និងមានសិទ្ធិចូលរួមក្នុងកិច្ចស៊ើបអង្កេត ("មតិយោបល់ចៅក្រម CHUNG និងចៅក្រម DOWNING"[19]។ ចៅក្រម CHUNG និងចៅក្រម DOWNING ក៏បានបញ្ចេញមតិថា ម្ចាស់បណ្ដឹងឧទ្ធរណ៍គួរទទួលបានឱកាសក្នុងការចូលរួមក្នុងកិច្ចស៊ើបអង្កេត នៅក្នុងដំណាក់កាលនេះក្នុងកិច្ចដំណើរការនីតិវិធី ដើម្បីធានាពីសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ រួមមានសិទ្ធិក្នុងការត្រៀមការការពារខ្លួន ដែលត្រូវបានធានាដោយមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[20]។

8. នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការចូលរួមកិច្ចស៊ើបអង្កេត ("សំណើសុំពិចារណាឡើងវិញ")[21] ដោយផ្អែកលើមូលដ្ឋានដែលថា ១) មតិយោបល់ចៅក្រម CHUNG និងចៅក្រម DOWNING អាចចាត់ទុកថាជាការផ្លាស់ប្ដូរនៃកាលៈទេសៈ[22] ២) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងដោយមិនពិចារណាថា ម្ចាស់បណ្ដឹងឧទ្ធរណ៍គឺជា "ជនត្រូវចោទ"

---

[18] ដូចជើងទំព័រខាងលើ មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ថុល, ចៅក្រម ហួត វុទ្ធី, កថាខណ្ឌ៨។

[19] ដូចជើងទំព័រខាងលើ មតិយោបល់របស់ចៅក្រម Chang-ho CHUNG និងចៅក្រម Rowan DOWNING, កថាខណ្ឌ ២៨។

[20] ដូចជើងទំព័រខាងលើ មតិយោបល់របស់ចៅក្រម Chang-ho CHUNG និងចៅក្រម Rowan DOWNING, កថាខណ្ឌ ២៥ ដល់២៧។

[21] ញត្តិរបស់ [redacted] ស្នើសុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើការស្នើសុំរបស់ក្រុមការពារក្ដីតា អាន ចូលពិនិត្យមើលសំណុំរឿង និងការចូលរួមក្នុងកិច្ចស៊ើបសួរ, ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារD121/4/4។

[22] ដូចជើងទំព័រខាងលើ កថាខណ្ឌ២៣។

ប៉ុន្តែបែរជាផ្តោតយ៉ាងតឹងរ៉ឹងទៅលើលក្ខខណ្ឌតម្រូវផ្លូវការសម្រាប់ការចោទប្រកាន់នៅអ.វ.ត.ក[23] និង ៣) បដិសេធមិនផ្តល់លទ្ធភាពដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការចូលទៅពិនិត្យមើលសំណុំរឿង ដែលបណ្តាលឱ្យមានភាពអយុត្តិធម៌ ដោយរំលោភទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង[24]។

9. នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ("សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីមួយ")[25] ដោយស្នើដល់សហចៅក្រមស៊ើបអង្កេតឱ្យស៊ើបអង្កេត [redacted][26] ហើយទទូចថា ការអនុវត្តដោយពេញលេញនូវការស៊ើបអង្កេតដូចបានរៀបរាប់ខាងលើ "អាចជាភស្តុតាងដោះបន្ទុក និងអាចបញ្ជាក់ពីទិដ្ឋភាពផ្សេងៗនៃអង្គហេតុដែលសំខាន់ដល់ការបញ្ជាក់ការពិត នៅក្នុងករណីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍"[27]។

---

[23] ដូចដើងទំព័រខាងលើ កថាខណ្ឌ២៨។

[24] ដូចដើងទំព័រខាងលើ កថាខណ្ឌ៣៥។

[25] សំណើលើកទី១ របស់ [redacted] សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៥៥ (១០), ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤, ឯកសារD187។

[26] ដូចដើងទំព័រខាងលើ កថាខណ្ឌ៣៣។

[27] ដូចដើងទំព័រខាងលើ កថាខណ្ឌ១៨។

10. នៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សំណើលើកទីពីរសុំបំពេញកិច្ចស៊ើបសួរ ("សំណើរលើកទីពីរ សុំបំពេញកិច្ចស៊ើបសួរ")[28] ស្នើសុំដល់សហចៅក្រមស៊ើបអង្កេតឱ្យស៊ើបអង្កេត [redacted][30]។

11. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់សំណើលើកទីបី សុំបំពេញកិច្ចស៊ើបសួរ ("សំណើលើកទីបីសុំបំពេញកិច្ចស៊ើបសួរ")[31] ដោយស្នើដល់សហចៅក្រមស៊ើបអង្កេត "បំពេញកិច្ចស៊ើបសួរឱ្យបានពេញលេញ [redacted]

---

[28] សំណើលើកទីពីរ របស់ [redacted] សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៥៥ (១០), ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៤, ឯកសារD188។

[29] ដូចជើងទំព័រខាងលើ កថាខណ្ឌ១។

[30] ដូចជើងទំព័រខាងលើ។

[31] សំណើលើកទីបីរបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៥៥(១០), ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៤, ឯកសារD189។

[32] ដូចជើងទំព័រខាងលើ កថាខណ្ឌ១។

[redacted][33]។

12. នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានច្រានចោលសំណើសុំពិចារណាឡើងវិញ ("សេចក្ដីសម្រេចលើការពិចារណាឡើងវិញ")[34] ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា មិនមានការផ្លាស់ប្ដូរកាលៈទេសៈ ភាពអយុត្តិធម៌ ឬកំហុសធ្ងន់ក្នុងការផ្ដល់សំអាងហេតុដែលអាចផ្ដល់នូវយុត្តិកម្មសម្រាប់ការពិចារណាឡើងវិញ លើសេចក្ដីសម្រេចស្ដីពីការចូលរួម ដែលមានអានុភាពចងកាតព្វកិច្ចរួចហើយ បន្ទាប់ពីអង្គបុរេជំនុំជម្រះមិនអាចឈានដល់ការចេញសេចក្ដីសម្រេច ចំពោះបណ្ដឹងឧទ្ធរណ៍លើការចូលរួម។

13. នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្ដីសម្រេចដែលរងការជំទាស់ បដិសេធសំណើទាំងបីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ សុំបំពេញកិច្ចស៊ើបសួរ ដោយផ្អែកលើមូលដ្ឋានថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលជា "ជនសង្ស័យ" គឺមិនមានសិទ្ធិដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទេ[35]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាថា ដោយសារតែឋានៈរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ គឺជាកម្មវត្ថុនៃសេចក្ដីសម្រេចចំនួនពីរ ដែលមិនត្រូវបានច្រានចោលពេលប្ដឹងឧទ្ធរណ៍ ហើយដោយសារមិនមានការផ្លាស់ប្ដូរកាលៈទេសៈ ដែលទាមទារឲ្យមានការពិចារណាឡើងវិញនោះ ការដាក់ទឡ្ហីករណ៍ឡើងវិញរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ គឺផ្ទុយទៅនឹងការសន្សំសំចៃធនធានរបស់តុលាការ[36]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា "ប្រសិនបើគ្មានការប្រែប្រួលឋានៈរបស់ជនសង្ស័យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងមិនទទួលយក

[33] ដូចជើងទំព័រខាងលើ។

[34] ដីកាសម្រេចលើសំណើពិចារណាឡើងវិញ លើសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ក្រុមមេធាវីការពារក្ដី [redacted] សុំពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត, ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D121/4/6។

[35] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៥។

[36] ដូចជើងទំព័រខាងលើ កថាខណ្ឌ៥ ដល់៦។

ហើយក៏មិនដាក់ចូលក្នុងសំណុំរឿង នូវសំណើបន្ថែមទៀតដែលដាក់តាងនាមឱ្យជនសង្ស័យ ដើម្បីស្នើឱ្យអនុវត្តសិទ្ធិដែលវិធានផ្ទៃក្នុង រក្សាទុកឱ្យជនត្រូវចោទ”[37]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានបញ្ចប់ថា ប្រសិនបើមានការប្រែប្រួលស្ថានភាពពាក់ព័ន្ធ ម្ចាស់បណ្ដឹងឧទ្ធរណ៍អាចដាក់សំណើសុំបំពេញកិច្ចស៊ើបសួរឡើងវិញ[38]។

## ខ. បណ្ដឹងឧទ្ធរណ៍

14. ម្ចាស់បណ្ដឹងឧទ្ធរណ៍បានដាក់បណ្ដឹងឧទ្ធរណ៍ជាភាសាអង់គ្លេស នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៤ និងជាភាសាខ្មែរនៅថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៤។ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបានតាមវិធាន ២១, វិធាន ៧៣(ក) និងវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ដោយសារតែបណ្ដឹងឧទ្ធរណ៍នេះ ប្រឆាំងនឹងសេចក្ដីសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ[39] និង “ពាក់ព័ន្ធនឹងការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជាមូលដ្ឋាន [របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍] ដែលជាចំណុចស្នូលនៃភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និងសមភាពនៃមធ្យោបាយនៃការតទល់ក្ដី”[40]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍លើកឡើងថា ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍មិនគួរត្រូវបានបដិសេធដោយផ្អែកលើ “ការអះអាងដោយភាន់ច្រឡំថា ម្ចាស់បណ្ដឹងឧទ្ធរណ៍ “មិនមែនជាជនត្រូវចោទ ហេតុដូច្នេះគាត់មិនអាចដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបានឡើយ”[41]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានទទួចថា គាត់មិនប្ដឹងឡើងវិញអំពីឋានៈរបស់គាត់នោះទេ ប៉ុន្តែគាត់លើកជាទឡ្ហីករណ៍ថា ក្នុងនាមជា “ជនសង្ស័យ” គាត់គួរត្រូវបានអនុញ្ញាតឱ្យដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់គាត់ ដែលត្រូវបានការពារដោយមាត្រា ១៤ នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងវិធាន ២១ នៃវិធានផ្ទៃក្នុង[42]។ ក្នុងផ្នែកអង្គសេចក្ដី ម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកទឡ្ហីករណ៍ថា សេចក្ដីសម្រេចដែលរងការជំទាស់មានកំហុសឆ្គងផ្នែកអង្គច្បាប់ព្រោះ ១) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្ដល់គោលបំណងស្របច្បាប់

---

[37] ដូចជើងទំព័រខាងលើ កថាខណ្ឌ៦។

[38] ដូចជើងទំព័រខាងលើ កថាខណ្ឌ៧។

[39] ដូចជើងទំព័រខាងលើ កថាខណ្ឌ៣៦។

[40] ដូចជើងទំព័រខាងលើ កថាខណ្ឌ៣៨។

[41] ដូចជើងទំព័រខាងលើ កថាខណ្ឌ៣៨។

[42] ដូចជើងទំព័រខាងលើ កថាខណ្ឌ២ និង ៤១។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRÉLIMINAIRE

ណាមួយ សម្រាប់ការកំហិតលើសិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ក្នុងការទទួលបានការការពារប្រកបដោយប្រសិទ្ធភាព និងការចូលពិនិត្យមើលសំណុំរឿងតុលាការ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង និងមាត្រា ១៤ នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[43] ២) សេចក្ដីសម្រេចដែលរងការជំទាស់បង្កការប៉ះពាល់ដល់សុចរិតភាព និងគុណភាពនៃកិច្ចស៊ើបសួរ ដោយបានបង្កហានិភ័យនៃការបាត់បង់ភស្តុតាងដោះបន្ទុក[44] ៣) សេចក្ដីសម្រេចដែលរងការជំទាស់បង្កហានិភ័យដោយការបដិសេធមិនផ្ដល់ដល់ម្ចាស់បណ្ដឹងឧទ្ធរណ៍នូវឱកាស ដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់ប្រឆាំងនឹងគាត់ ដូច្នេះនឹងបណ្ដាលឱ្យគាត់ទទួលរងព្យសនកម្ម[45] និង ៤) សេចក្ដីសម្រេចដែលរងការជំទាស់មិនបានផ្ដល់សំអាងហេតុគ្រប់គ្រាន់ និងមិនបានដោះស្រាយដល់រាល់ទឡ្ហីករណ៍ដែលបានលើកឡើងដោយម្ចាស់បណ្ដឹងឧទ្ធរណ៍ ដូចដែលតម្រូវឱ្យមាននូវមតិយោបល់របស់ចៅក្រម តាមច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងបទដ្ឋានអន្តរជាតិ[46]។ ជាលទ្ធផល ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើដល់អង្គបុរេជំនុំជម្រះ "បដិសេធសេចក្ដីសម្រេចដែលរងការជំទាស់ និងបញ្ជាឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ដែលជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នេះ និងបង្គាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុញ្ញាតឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍ ចូលរួមនៅក្នុងកិច្ចស៊ើបសួរដោយតុលាការ តាមរយៈការដាក់សំណើបន្ថែមសុំបំពេញកិច្ចស៊ើបសួរ ដែលចាំបាច់ដើម្បីការពារផលប្រយោជន៍របស់គាត់"[47]។

15. សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានដាក់ចម្លើយតប ចំពោះបណ្ដឹងឧទ្ធរណ៍ តាមកាលបរិច្ឆេទកំណត់តាមផ្លូវច្បាប់ឡើយ។

## គ. ទឡ្ហីករណ៍ផ្ទាល់មាត់

16. ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើដល់អង្គបុរេជំនុំជម្រះ សុំបើកសវនាការជាសាធារណៈ លើបណ្ដឹងឧទ្ធរណ៍ ដោយបានលើកឡើងថា ដើម្បីជាផលប្រយោជន៍យុត្តិធម៌ ដោយសារតែសេចក្ដីសម្រេច

[43] ដូចដើងទំព័រខាងលើ កថាខណ្ឌ៤៣ ដល់៤៨។

[44] ដូចដើងទំព័រខាងលើ កថាខណ្ឌ៤៩ ដល់៥៣។

[45] ដូចដើងទំព័រខាងលើ កថាខណ្ឌ៥៤ ដល់៥៧។

[46] ដូចដើងទំព័រខាងលើ កថាខណ្ឌ៥៨ ដល់៥៩។

[47] ដូចដើងទំព័រខាងលើ កថាខណ្ឌ១។

ដែលរងការជំទាស់ បានបណ្តាលឲ្យមានជាការរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់[48]។

17. វិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុងចែងថា "បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ"។ ដោយបានពិចារណាលើសារណាជាលាយលក្ខណ៍អក្សរយ៉ាងច្រើនដែលបានធ្វើឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ និងដោយសារមិនមានចម្លើយតបណាមួយដែលបានដាក់ដោយព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណីនោះ អង្គបុរេជំនុំជម្រះពិចារណាថា មិនមានភាពចាំបាច់ក្នុងការបើកសវនាការផ្ទាល់មាត់ នៅក្នុងករណីនេះឡើយ ហើយសម្រេចចេញសេចក្តីសម្រេចរបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍នេះ។

## II. **ការវិភាគ**

18. ដូចដែលបានបង្ហាញពីខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចនៅក្នុងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើការចូលរួមថា ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលមិនមែនជាជនត្រូវចោទនោះ មិនមានសិទ្ធិចូលរួមក្នុងកិច្ចស៊ើបអង្កេតនៅដំណាក់កាលនេះឡើយ ដោយអនុលោមតាមវិធានផ្ទៃក្នុង[49] ឬក្នុងន័យទូលាយ តាមសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌[50]។ ការយល់ឃើញនេះ បើទោះបីជាត្រូវបានបង្ហាញក្នុងលក្ខណៈទូទៅ ប៉ុន្តែបានគ្រប់ដណ្តប់ពេញលេញលើការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ[51]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើការចូលរួម ទៅអង្គបុរេជំនុំជម្រះរួចហើយ ប៉ុន្តែមិនអាចទទួលបានជោគជ័យ ក្នុងការបដិសេធលើសេចក្តីសម្រេចនេះ ព្រោះអង្គបុរេជំនុំជម្រះមិនអាចស្វែងរកសំឡេងភាគច្រើនបួននាក់ ដូចដែលតម្រូវតាមមាត្រា ៧៧(១៣) នៃវិធានផ្ទៃក្នុង ដើម្បីចេញសេចក្តីសម្រេច។ ជាលទ្ធផល សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើការចូលរួម បានក្លាយជាសេចក្តីសម្រេចស្ថាពរ។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានស្នើដល់

---

[48] ដូចដើងទំព័រខាងលើ កថាខណ្ឌ៣ និង៤។

[49] សូមមើលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើការចូលរួម, កថាខណ្ឌ ៣៦ ដល់៤៩ និង៦២។

[50] ដូចដើងទំព័រខាងលើ កថាខណ្ឌ៥០ ដល់៦២។

[51] ដូចដើងទំព័រខាងលើ កថាខណ្ឌ៣៧, ៤៦, ៥៥, ៥៩ និង ៦២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឱ្យធ្វើការពិចារណាឡើងវិញលើសេចក្តីសម្រេចខាងលើ ដោយផ្អែកលើមូលដ្ឋាននៃមតិយោបល់ ដែលលើកឡើងដោយចៅក្រម CHUNG និងចៅក្រម DOWNING ប៉ុន្តែសំណើនេះត្រូវបានបដិសេធ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅតែអះអាងឡើងវិញពីគោលជំហរដូចដើមរបស់គាត់។

19. ទោះបីជាបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធសំណើជាក់លាក់ចំនួនបី សុំបំពេញកិច្ចស៊ើបសួរក៏ដោយ តែទឡ្ហីករណ៍ដែលបានលើកឡើងពាក់ព័ន្ធដល់ "សិទ្ធិ" របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដោយមិនគិតដល់ខ្លឹមសារនោះឡើយ។ ជាពិសេស ម្ចាស់បណ្តឹងឧទ្ធរណ៍បានអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះថា ការគោរពដល់សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់ តម្រូវថា គាត់ត្រូវទទួលបានការអនុញ្ញាតឱ្យដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ[52]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងថា ការបដិសេធមិនផ្តល់ឱកាសដល់គាត់ ក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ អាចបណ្តាលឱ្យបាត់បង់ភស្តុតាងដោះបន្ទុក ប្រសិនបើសាក្សីសក្តានុពលមិនអាចស្វែងរកបាន[53] ហើយនឹងបង្កើតបានជាហានិភ័យដែលថា សកម្មភាពស៊ើបអង្កេតមិនអាចអនុវត្តបានមុនពេលបិទបញ្ចប់កិច្ចស៊ើបសួរ ដោយសារតែកង្វះធនធាន[54]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទឡ្ហីករណ៍ទាំងនេះមានលក្ខណៈទូទៅ និងគ្រាន់តែជាការទាយស្មាន ដោយសារតែមិនមានការលើកឡើងពីអំណះអំណាងណាមួយដែលថា សំណើណាមួយក្នុងចំណោមសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី ដែលពាក់ព័ន្ធដល់បណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ ស្វះស្វែងរកការស្តាប់ចម្លើយសាក្សីណាម្នាក់ ដែលមានហេតុផលគ្រប់គ្រាន់សម្រាប់ការភ័យខ្លាចថា សាក្សីទាំងនោះអាចរកមិនបាន ឬក៏អាចផ្តល់ជាយុត្តិកម្មសម្រាប់ការចាំបាច់ខានមិនបាន ក្នុងការអនុវត្តកិច្ចស៊ើបសួរដែលបានស្នើឡើងនោះ។ ម្ចាស់បណ្តឹងឧទ្ធរណ៍បែរជាមិនលើកឡើងថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការមិនសម្រេចទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី នៅដំណាក់កាល

[52] *សូមមើលជាឧទាហរណ៍* បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ២, ៣៩ ដល់៤២, ៤៧។ សូមមើលផងដែរ សេចក្តីសន្និដ្ឋាន នៅកថាខណ្ឌ ៦០(ឃ) ដែលបានស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យបង្គាប់ដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឱ្យអនុញ្ញាតដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ឱ្យដាក់ "សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀត ដែលចាំបាច់សម្រាប់ការការពារផលប្រយោជន៍របស់គាត់"។

[53] ដូចជើងទំព័រខាងលើ កថាខណ្ឌ៥២។

[54] ដូចជើងទំព័រខាងលើ កថាខណ្ឌ៥៤ ដល់៥៦។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

នេះ បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរច្បាស់លាស់ទៅលើ សិទ្ធិទទួលបានជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា បណ្តឹងឧទ្ធរណ៍មិនបានលើកឡើងពីអង្គហេតុ ឬកាលៈទេសៈថ្មីណាមួយឡើយ ប៉ុន្តែបែរជាអះអាងឡើងវិញនូវទឡ្ហីករណ៍ដែលបានលើកឡើងរួចមកហើយនៅក្នុងបណ្តឹងឧទ្ធរណ៍លើការចូលរួម[55]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍ព្យាយាមលើកយកមកដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ នូវបញ្ហាដែលទាំងក្នុងអង្គហេតុ និងអង្គច្បាប់ ដែលបញ្ហាទាំងនេះត្រូវបានត្រួតពិនិត្យរួចរាល់ហើយនៅក្នុងការពិចារណាលើបណ្តឹងឧទ្ធរណ៍ (ឧទាហរណ៍ សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការចូលរួមក្នុងកិច្ចស៊ើបអង្កេត) ហើយដែលអង្គបុរេជំនុំជម្រះមិនអាចស្វែងរកសំឡេងភាគច្រើនលើសលប់ ចំនួនបួនសំឡេង ដើម្បីចេញសេចក្តីសម្រេចបានឡើយ។

20. ប្រសិនបើអង្គជំនុំជម្រះធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន គឺអាចសន្មតបានថា ចៅក្រមទាំងប្រាំរូបរបស់អង្គបុរេជំនុំជម្រះ នឹងមានមតិយោបល់ដូចមតិយោបល់លើកមុនរបស់ខ្លួន ហើយចៅក្រមនីមួយៗនឹងឈានដល់សេចក្តីសន្និដ្ឋានដដែល ដែលនឹងបង្កឲ្យមានលទ្ធផលដូចគ្នាចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍ ដូចជាថា សេចក្តីសម្រេចដែលរងការជំទាស់នឹងត្រូវតម្កល់ទុកជាបានការដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង។ ស្ថានភាពបែបនេះបង្ហាញថា បណ្តឹងឧទ្ធរណ៍មិនមានប្រយោជន៍ ហើយបង្កើតជាលទ្ធភាពនៃការប្តឹងដែលគ្មានទីបញ្ចប់។ អង្គបុរេជំនុំជម្រះសូមសង្កត់ធ្ងន់ថា វិធានស្តីពីសម្លេងភាគច្រើនលើសលប់ និងស្ថានភាពដូចដើម ដែលត្រូវបានប្រមើលមើលក្នុងវិធានផ្ទៃក្នុង គឺជាលក្ខណៈពិសេសសម្រាប់តែ អ.វ.ត.ក ដែលអាចបណ្តាលឲ្យអង្គជំនុំជម្រះមិនអាចឈានទៅរកសេចក្តីសម្រេចបាននៅលើបញ្ហាជាក់លាក់ណាមួយ។ ក្នុងន័យនេះ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងចែងថា៖

> ១៣. សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម៤ (បួន) រូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសំឡេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖

[55] *សូមមើលជាឧទាហរណ៍* បណ្តឹងឧទ្ធរណ៍លើការចូលរួម កថាខណ្ឌ ១៧ ដល់២៤, ៦១ ដល់៨០

01028993



ក. ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំមោឃភាពដីកា ឬកិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬកិច្ចស៊ើបសួរនោះត្រូវតម្កល់ទុកជាបានការ។

ខ. ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសំឡេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

នៅពេលដែលអង្គបុរេជំនុំជម្រះមិនអាចសម្រេចលើបញ្ហាដែលបានលើកឡើងនៅចំពោះមុខខ្លួន ការត្រួតពិនិត្យឡើងវិញលើបញ្ហាដែលដូចគ្នាជាសំខាន់ ទាំងក្នុងអង្គហេតុ និងអង្គច្បាប់ តាមរយៈសំណើសុំ ឬបណ្តឹងឧទ្ធរណ៍ដែលដាក់សាជាថ្មី ដោយភាគីដដែល នឹងផ្ទុយទៅនឹងគោលការណ៍នៃសច្ចភាពផ្លូវច្បាប់[56] និងការសន្សំសំចៃធនធានរបស់តុលាការ ហើយក្នុងលក្ខណៈទូទៅជាងនេះ គឺផ្ទុយទៅនឹងផលប្រយោជន៍យុត្តិធម៌ ដោយសារតែការណ៍នេះនឹងមិនជួយជំរុញកិច្ចដំណើរការនីតិវិធី ប៉ុន្តែបែរជាប្រឈមហានិភ័យនៃការបង្កឲ្យមានការពន្យារពេល។ ការស្វែងរកគោលការណ៍ណែនាំនៅក្នុងវិធាននីតិវិធី នៅកម្រិតអន្តរជាតិ អនុលោមតាមមាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២៣ថ្មី និងមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ២ វិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា បើតាមសទិសភាព ការបដិសេធចោលញត្តិ ឬសំណើសុំ ដោយផ្អែកលើមូលដ្ឋានដែលថា ញត្តិ ឬសំណើសុំនោះលើកឡើងនូវបញ្ហាដែលត្រូវបានសម្រេចរួចហើយ ដោយសេចក្តីសម្រេចស្ថាពរ ដែលមានអានុភាពចងកាតព្វកិច្ចលើភាគីដែលពាក់ព័ន្ធ (ដូច្នេះគឺជាបញ្ហាដែលជំនុំជម្រះរួចហើយ) គឺជាការអនុវត្តជាទូទៅនៅតាមតុលាការដទៃទៀតដែលមានលក្ខណៈអន្តរជាតិ លើកលែងតែបញ្ហាទាំងអស់នេះ ត្រូវបានលើកឡើងនៅក្នុងបរិបទនៃសំណើសុំឲ្យ

[56] *សូមមើល* វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Aleksovski*, IT-95-14/1-A, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល, កថាខណ្ឌ ៩៧ (ដែលអង្គជំនុំជម្រះតុលាការកំពូល របស់តុលាការ ICTY បានរំឭកថា ភាពចាំបាច់សម្រាប់ "សង្គតភាព សច្ចភាព និង ភាពអាចប៉ាន់ប្រមាណ" នៅក្នុងអង្គច្បាប់ ត្រូវបានទទួលស្គាល់ជាទូទៅនៅក្នុងយុត្តាធិការជាតិ ទាំងក្នុងប្រព័ន្ធ Common law និងCivil law ព្រមទាំងនៅចំពោះមុខតុលាការអន្តរជាតិ")។

ពិចារណាឡើងវិញ[57]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា ខ្លួនអាចបដិសេធបណ្តឹងឧទ្ធរណ៍ ឬសំណើសុំមួយ ដោយមិនធ្វើការពិចារណាទៅលើភាពអាចទទួលយកបានជាផ្លូវការរបស់បណ្តឹងឧទ្ធរណ៍ ឬសំណើនោះ តាមវិធាន ៧៣, វិធាន ៧៤ និង/ឬ វិធាន ២១ ឬទៅលើអង្គសេចក្តីនោះឡើយ នៅពេលដែលបណ្តឹង ឬសំណើនោះ បានលើកឡើងពីបញ្ហាមួយដែលដូចគ្នាយ៉ាងខ្លាំង (ទាំងក្នុងអង្គហេតុ និងអង្គច្បាប់) ទៅនឹងបញ្ហាដែលត្រូវបានត្រួតពិនិត្យរួចហើយដោយអង្គជំនុំជម្រះ

---

[57] *សូមមើលជាឧទាហរណ៍ រដ្ឋអាជ្ញា តទល់នឹង Simic និងអ្នកដទៃទៀត,* IT-95-9, សេចក្តីសម្រេចលើ (១) សំណើរបស់ Steven Todorovic សុំពិចារណាឡើងវិញលើសេចក្តីសម្រេចថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩ (២) ញត្តិរបស់ ICRC សុំឱ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ និង (៣) លក្ខខណ្ឌសម្រាប់ការចូលពិនិត្យមើលសំណុំរឿង, អង្គជំនុំជម្រះសាលាដំបូង ៣, ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០០, កថាខណ្ឌ ៩ ("គោលការណ៍នៃការជំនុំជម្រះរួចហើយ នឹងរារាំងដល់រដ្ឋអាជ្ញា មិនឱ្យលើកឡើងនូវបញ្ហាដាក់លាក់ម្តងទៀត នៅក្នុងកិច្ចដំណើរការនីតិវិធីបន្ទាប់បន្សំនានា រវាងរដ្ឋអាជ្ញា និង ICRC លើកលែងតែករណីដែលអង្គជំនុំជម្រះសាលាដំបូង ខ្លួនឯងបានត្រៀមខ្លួនក្នុងការពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួន")។ *រដ្ឋអាជ្ញា តទល់នឹង Prlicនិងអ្នកដទៃទៀត*, IT-04-74-T, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី សុំការបញ្ជាក់ ដើម្បីប្តឹងឧទ្ធរណ៍, អង្គជំនុំជម្រះសាលាដំបូង ៣, ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩, ទំព័រ ៣ (ដែលអនុវត្តគោលការណ៍ ជំនុំជម្រះរួចហើយ ចំពោះបញ្ហានីតិវិធី ដែលត្រូវបានដោះស្រាយរួចរាល់ហើយ)។ *រដ្ឋអាជ្ញា តទល់នឹង Rutoនិងអ្នកដទៃទៀត,* ICC-01/09-01/11, សេចក្តីសម្រេចលើ "សំណើរបស់រដ្ឋាភិបាលប្រទេសកេនយ៉ា ពាក់ព័ន្ធនឹងការបញ្ជាក់អះអាងពីកិច្ចដំណើរការនីតិវិធីនៃការចោទប្រកាន់", អង្គបុរេជំនុំជម្រះ ២, ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ៨ (យល់ឃើញថារដ្ឋាភិបាលកេនយ៉ា បានជំទាស់ទៅលើភាពអាចទទួលយកបាននៃរឿងក្តី "ជំនុំជម្រះរួចហើយ"។ *រដ្ឋអាជ្ញា តទល់នឹង Ntakirutimana និងអ្នកដទៃទៀត,* ICTR-96-10-I និង ICTR-96-17-T, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា សុំបញ្ចូលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ICTR-96-10-IជាមួយនិងICTR-96-17-T, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១, កថាខណ្ឌ ១១ ("ប្រសិនបើអង្គជំនុំជម្រះបានសម្រេចរួចរាល់ហើយលើបញ្ហាអង្គហេតុ ទោះបីជាការសម្រេចនោះដើម្បីសំណើសុំផ្សេង ឬក៏វិធានផ្សេងក៏ដោយ អង្គជំនុំជម្រះ នឹងមិនពិចារណាឡើងវិញលើបញ្ហានេះឡើយ ស្ថិតក្រោមកម្មវត្ថុនៃមូលដ្ឋានថ្មីដែលត្រូវលើកឡើង")។ *សូមមើលផងដែរ* អំពីគោលការណ៍ ជំនុំជម្រះរួចហើយ (ដូចដែលបានអនុវត្តចំពោះ "សាលក្រម" លើអង្គសេចក្តី ឬលើអញ្ញត្រកម្ម ពាក់ព័ន្ធយុត្តាធិការ)៖ តុលាការយុត្តិធម៌អន្តរជាតិ, *រឿងក្តីពាក់ព័ន្ធការអនុវត្តអនុសញ្ញាស្តីពីការរារាំង និងដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (Bosnia and Herzegovina តទល់នឹង Serbia and Montenegro)*, សាលក្រម, ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧, របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ២០០៧, ទំព័រ ៤៣ កថាខណ្ឌ ១១៤ ដល់ ១២០។ ស្រដៀងគ្នានេះ នៅតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស សំណើមួយត្រូវបានប្រកាសថាមិនអាចទទួលយកបាន នៅពេលដែលសំណើនោះ "ដូចគ្នាទៅនឹងបញ្ហាដែលតុលាការបានត្រួតពិនិត្យរួចហើយ" ឧទាហរណ៍ "នៅពេលដែលភាគី, អ្នកប្តឹង និងអង្គហេតុដូចគ្នាបេះបិទ"។ សូមមើល មាត្រា ៣៥(២)(ខ) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស, គោលការណ៍អនុវត្តស្តីពីលក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបាន, ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១១, កថាខណ្ឌ ១០៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ពាក់ព័ន្ធទៅនឹងភាគីតែមួយ ហើយដែលអង្គជំនុំជម្រះមិនអាចស្វែងរកសម្លេងភាគច្រើនលើសលប់បួនសម្លេង សម្រាប់ការចេញសេចក្តីសម្រេច។

21. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍ ដោយមិនធ្វើការពិចារណាទៅលើភាពអាចទទួលយកបានរបស់បណ្តឹងឧទ្ធរណ៍នេះ តាមវិធាន ៧៣, វិធាន ៧៤ និងវិធាន ២១ នៃវិធានផ្ទៃក្នុង ឬទៅលើអង្គសេចក្តីនោះឡើយ។

## III. ផ្នែកសម្រេចសេចក្តី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

បដិសេធបណ្តឹងឧទ្ធរណ៍នេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** Rowan DOWNING **ណី ថុល** Chang-ho CHUNG **ហួត វុទ្ធី**